ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល

# ដំណឹងជ្រើសរើសបុគ្គលិក

**យោង៖**
- កំណត់បង្ហាញលេខ ០៣៣/១៦ ប.ល/ស.វ.ស ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៦ របស់ផ្នែកបុគ្គលិក នៃ ស.វ.ស។
- ចំណារឯកភាព ចុះថ្ងៃទី ២៨ ខែមីនា ឆ្នាំ២០១៦ របស់ឯកឧត្តមសាកលវិទ្យាធិការ នៃ ស.វ.ស។

សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល គឺជាសាកលវិទ្យាល័យបណ្តុះបណ្តាលវិស័យសុខាភិបាល ដែលមានវ័យចំណាស់ជាងគេបំផុត នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ត្រូវការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ចំនួន **០១**រូប សម្រាប់បម្រើការងារនៅ**ផ្នែកកិច្ចការនិស្សិត** នៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ដែលត្រូវមានភារកិច្ច និង គុណវុឌ្ឍិ ដូចខាងក្រោម៖

| ភារកិច្ច | គុណវុឌ្ឍិ |
|---|---|
| ០១-រៀបចំទុកដាក់ឯកសារផ្នែកឲ្យមានរបៀបរៀបរយងាយស្រួលតាមដាន<br>០២-ទំនាក់ទំនងជាមួយនិស្សិត ស.វ.ស ថ្នាក់ដឹកនាំមហាវិទ្យាល័យ/សាលា ថ្នាក់ដឹកនាំសាកលវិទ្យាល័យ និង ផ្នែកពាក់ព័ន្ធ<br>០៣-ចូលរួមរៀបចំផែនការកិច្ចការនិស្សិតប្រចាំឆ្នាំ ឲ្យសមស្របនឹងតម្រូវការបច្ចុប្បន្នភាពរបស់និស្សិត<br>០៤-ចូលរួមរៀបចំកិច្ចប្រជុំ សិក្ខាសាលានិងព្រឹត្តិការណ៍នានាទាក់ទងនឹងកិច្ចការនិស្សិត ស.វ.ស<br>០៥-ចូលរួមស្រាវជ្រាវឯកសារផ្សេងៗពាក់ព័ន្ធនឹងការអភិវឌ្ឍសេវានិស្សិត និង ការស្រាវជ្រាវទាក់ទងនឹងសេវានិស្សិត<br>០៦-ចូលរួមប្រឹក្សា ពិគ្រោះយោបល់ជាមួយគ្រូបង្រៀន គ្រូបង្គាត់ គ្រូណែនាំកម្មសិក្សា ថ្នាក់ដឹកនាំមហាវិទ្យាល័យ/សាលា និង ផ្នែកពាក់ព័ន្ធ ដើម្បីផ្តល់សេវានិស្សិតប្រកប ដោយគុណភាព<br>០៧-ធ្វើរបាយការណ៍ប្រចាំខែ/ត្រីមាស/ឆ្នាំ របស់ផ្នែកកិច្ចការនិស្សិត ស.វ.ស ដើម្បីបញ្ជូនទៅឯកឧត្តមសាកលវិទ្យាធិការ<br>០៨-មានគំនិតច្នៃប្រឌិតក្នុងការ Design ផ្សេងៗ លើ Flyer និង លើវត្ថុអនុស្សាវរីយ៍ផ្សេងៗ<br>០៩-គោរពតាមការចាត់តាំងរបស់ប្រធាននិងការចាត់តាំងផ្សេងៗ របស់ ស.វ.ស។ | - មានសញ្ញាបត្រចាប់ពីថ្នាក់បរិញ្ញាបត្រឡើងទៅ<br>- មានជំនាញខាងទំនាក់ទំនងសាធារណៈ<br>- ចេះភាសាបារាំង និង អង់គ្លេសសម្រាប់ប្រើប្រាស់ក្នុងផ្នែកកិច្ចការនិស្សិត<br>- ចេះប្រើប្រាស់កម្មវិធី Word, Excel, Powerpoint និង Photoshop<br>- មានសីលធ៌មរស់នៅល្អ ថ្លៃថ្នូរ ស្លូតបូត គោរពគ្នាទៅវិញទៅមក និង គោរពវិន័យ ស.វ.ស បានល្អ<br>- មានស្មារតីទទួលខុសត្រូវ និង តម្លាភាពក្នុងការងារ<br>- មានស្មារតីធ្វើការងារជាក្រុម និង មានអំណត់អត់ធន់ក្នុងការងារ<br>- ស្រលាញ់កិច្ចការទំនាក់ទំនង និង មានភាពប៉ិនប្រសព្វក្នុងកិច្ចការទំនាក់ទំនង ប្រកបដោយប្រសិទ្ធភាព<br>-មានបទពិសោធន៍ក្នុងកិច្ចការងារទំនាក់ទំនងជាមួយនិស្សិតយ៉ាងហោច ០១ឆ្នាំ<br>- ចូលចិត្ត និង ចូលរួមក្នុងកម្មវិធីសប្បុរសធម៌ផ្សេងៗ<br>- ចូលចិត្តការធ្វើ Design ផ្សេងៗប្រកបដោយគំនិតច្នៃប្រឌិត<br>- មានអាយុយ៉ាងតិច ១៨ឆ្នាំ |

**អត្ថប្រយោជន៍ដែលទទួលបាន៖**
- ប្រាក់ក្នុងបុណ្យចូលឆ្នាំខ្មែរ បុណ្យភ្ជុំបិណ្ឌ និង ឱកាសទិវាសិទ្ធនារី (សម្រាប់នារី)
- ប្រាក់លើកទឹកចិត្តប្រចាំឆ្នាំ (ចំពោះបុគ្គលិកដែលបានបម្រើការងារចាប់ពី ០១ឆ្នាំឡើងទៅ)
- ឱកាសក្នុងការបណ្តុះបណ្តាលជំនាញបន្ត។

**ព័ត៌មានលម្អិត៖**
- បើបេក្ខជនមានចំណាប់អារម្មណ៍ **សូមទំនាក់ទំនងជាមួយផ្នែកបុគ្គលិក នៃ ស.វ.ស ដើម្បីបំពេញពាក្យសុំចូលបម្រើការងារ ឬ អាចទាញយកទម្រង់ពាក្យសុំនេះនៅលើវេបសាយ (www.uhs.edu.kh) រួចផ្ញើមកផ្នែកបុគ្គលិក (បន្ទប់ M109) ឲ្យបានមុនថ្ងៃទី២៩ ខែ មេសា ឆ្នាំ២០១៦ វេលាម៉ោង ១៦:00 រសៀលជាកំហិត។**
- អាស័យដ្ឋានទំនាក់ទំនង៖ ឡូតិ៍លេខ៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឬ តាមទូរស័ព្ទលេខ **023 430 559 / 089 383 338 / 077 456 070 / 012 961 529 / 015 575 554** E-Mail: orn_samnang@uhs.edu.kh ។

**បញ្ជាក់៖**
- សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល រក្សាសិទ្ធិក្នុងការធ្វើបញ្ជីឈ្មោះជ្រើសរើសបេក្ខជន (Short List) និង កំណត់ថ្ងៃខែ សម្ភាសន៍ លើកពេលកែប្រែ និង លុបចោលការជ្រើសរើសក្នុងករណីមានភាពមិនប្រក្រតី។
- បេក្ខនារី ត្រូវបានលើកទឹកចិត្តក្នុងការដាក់ពាក្យ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ មីនា ឆ្នាំ២០១៦

**ប្រធានផ្នែកបុគ្គលិក**

**ប៊ុន_ធីរ៉ាត់**